# ព្រះរាជក្រម

នស/រកម/០៧០៧/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឈរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការការពារនិងការលើកស្ទួយភាពផ្សេងៗគ្នា នៃ វិញ្ញត្តិវប្បធម៌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និង ការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលអនុម័តកាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ នៅទីក្រុងប៉ារីស ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧

៧/ល.០៧០៧.៣១២

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
រដ្ឋមន្ត្រីស្តីទី

**ហត្ថលេខា**

**ហ៊ឹម ឆែម**

លេខៈ ៣០៦ ធ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ... ឆ្នាំ២០០៧

# អនុសញ្ញា ស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

ទីក្រុងប៉ារីស ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥

# អនុសញ្ញាស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

អនុសញ្ញាស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

សន្និសីទទូទៅ នៃអង្គការយូណេស្កូ ដែលបានធ្វើឡើងនៅទីក្រុងប៉ារីស ពីថ្ងៃទី០៣ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ សម្រាប់សម័យប្រជុំលើកទី៣៣របស់ខ្លួន

*ដោយអះអាងថា* ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាចរិតលក្ខណៈមួយមានពីកំណើតរបស់មនុស្សជាតិ

*ដោយយល់ឃើញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ និងគួរតែត្រូវបានលើកតម្កើង និងថែរក្សា ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិទាំងអស់

*ដោយដឹងថា* ភាពផ្សេងៗគ្នានៃវប្បធម៌បង្កើតបានពិភពមួយពោរពេញទៅដោយភាពសម្បូរបែប និងភាពប្លែកៗគ្នាដែលពង្រីកនូវលទ្ធភាពជម្រើសបានច្រើន បណ្តុះនូវសមត្ថភាព និងតម្លៃមនុស្ស ហើយភាពផ្សេងៗគ្នានៃវប្បធម៌គឺជាកំលាំងគ្រឹះនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសហគមន៍ ប្រជាជន និងប្រជាជាតិ

*ដោយរំលឹកឡើងវិញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ដែលរីកលូតលាស់នៅក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យ ភាពសណ្តោសអត់ឱន យុត្តិធម៌សង្គម និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជន និង ប្រជាជន រវាងវប្បធម៌ និងវប្បធម៌ គឺជាកត្តាចាំបាច់ខាងមិនបានដល់សន្តិភាព និងសន្តិសុខក្នុងតំបន់ ជាតិ និងអន្តរជាតិ

*ដោយលើកតម្កើង* សារៈសំខាន់នៃភាពផ្សេងៗគ្នានៃវប្បធម៌ដើម្បីធ្វើឱ្យសម្រេចបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ក៏ដូចជានៅក្នុងលិខិតូបករណ៍ដទៃទៀតដែលត្រូវបានទទួលស្គាល់ជាសាកល

*ដោយគូសបញ្ជាក់* ពីភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មវប្បធម៌ជាធាតុផ្សំយុទ្ធសាស្ត្រទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងទៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍន៍ ដោយចាប់អារម្មណ៍ផងដែរទៅលើសេចក្តីថ្លែងការណ៍សហសវត្សរបស់អង្គការសហប្រជាជាតិ(ឆ្នាំ២០០០) ដែលផ្តោតលើការលុបបំបាត់ភាពក្រីក្រ

*ដោយសង្កេតឃើញថា* វប្បធម៌មានទម្រង់ប្លែកៗគ្នាទៅតាមកាលវេលា និងទីកន្លែង ហើយ *ដោយសង្កេតឃើញថា* ភាពប្លែកៗគ្នានេះចាប់បដិសន្ធិឡើងនៅក្នុងភាពថ្មីប្លែកពីគេ និងក្នុងពហុភាព

នៃអត្តសញ្ញាណ ព្រមទាំងនៅក្នុងវិញ្ញត្តិវប្បធម៌របស់ប្រជាជន និងសង្គមដែលរួមផ្សំ បង្កើតជាមនុស្សជាតិ

*ដោយទទួលស្គាល់* សារៈសំខាន់នៃចំណេះដឹងជាប្រពៃណី ជាប្រភពនៃធនធានអរូបី និងរូបី និងជាពិសេសសារៈសំខាន់នៃប្រព័ន្ធចំណេះដឹងរបស់ប្រជាជនម្ចាស់ស្រុក ហើយដោយទទួលស្គាល់នូវការរួមចំណែកជាវិជ្ជមាននៃចំណេះដឹងទាំងនេះដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងភាពចាំបាច់ក្នុងការការពារ និងលើកស្ទួយចំណេះដឹងទាំងនេះឱ្យបានសមស្រប

*ដោយទទួលស្គាល់* ភាពចាំបាច់ក្នុងការចាត់វិធានការដើម្បីការពារភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រួមទាំងខ្លឹមសារចម្រុះរបស់វាផងដែរ ជាពិសេសនៅក្នុងស្ថានភាពដែលភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌អាចទទួលរងនូវការគំរាមកំហែងផុតរលត់ ឬការខូចខាតធ្ងន់ធ្ងរ

*ដោយកត់សំគាល់ឃើញពី* សារៈសំខាន់របស់វប្បធម៌ក្នុងការធ្វើឱ្យមានសាមគ្គីភាពក្នុងសង្គមជាទូទៅ និងជាពិសេសការចូលរួមចំណែករបស់វប្បធម៌ក្នុងការលើកស្ទួយឋានៈ និងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម

*ដោយយល់ឃើញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ត្រូវបានពង្រឹងដោយការផ្លាស់ប្តូរគំនិតគ្នាដោយសេរី និងដោយយល់ឃើញថា ភាពផ្សេងៗគ្នានៃវប្បធម៌ធ្វើឱ្យមានការផ្លាស់ប្តូរជាច្រើនព្រមទាំងធ្វើឱ្យមានអន្តរកម្ម រវាងវប្បធម៌ និងវប្បធម៌

*ដោយបញ្ជាក់ឡើងវិញថា* សេរីភាពនៃការគិត ការបញ្ចេញមតិ និងការទទួលបានព័ត៌មាន ព្រមទាំងពហុប្រព័ន្ធផ្សព្វផ្សាយអាចធ្វើឱ្យមានការរីកលូតលាស់ដល់វិញ្ញត្តិវប្បធម៌នៅក្នុងសង្គមនីមួយៗ

*ដោយទទួលស្គាល់ថា* ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រួមទាំងវិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីនានា គឺជាកត្តាដ៏សំខាន់ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗ និងប្រជាជនធ្វើការបកស្រាយ បង្ហាញ និង ចែករំលែកគំនិត ព្រមទាំងតម្លៃរបស់ខ្លួនជាមួយអ្នកដទៃ

*ដោយរំលឹកឡើងវិញថា* ភាពផ្សេងៗគ្នានៃភាសា គឺជាធាតុផ្សំគ្រឹះមួយនៃភាពផ្សេងៗគ្នានៃវប្បធម៌ និង*ដោយបញ្ជាក់ឡើងវិញ*ពីតួនាទីជាមូលដ្ឋាននៃការអប់រំនៅក្នុងការការពារ និងការលើកស្ទួយនូវវិញ្ញត្តិវប្បធម៌នានា

*ដោយសង្កេតឃើញពី* សារៈសំខាន់នៃភាពរៀវក្លារបស់វប្បធម៌សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងសម្រាប់មនុស្សក្នុងក្រុមជនជាតិភាគតិច និងសម្រាប់ប្រជាជនម្ចាស់ស្រុក ដូចដែលវាស្តែងឡើងតាមរយៈសេរីភាពរបស់ពួកគេក្នុងការបង្កើត ផ្សព្វផ្សាយ និងចែកចាយនូវ វិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីរបស់ពួកគេ និងចូលរួមដើម្បីជួយសម្រួលដល់ការអភិវឌ្ឍន៍របស់ខ្លួនគេផ្ទាល់